ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ: ១១៩
ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៩
សាលដីកា
លេខ: ៤២ "V"
ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០

# សាលដីកា

## តាងនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០

ដោយមានសមាសភាពអង្គជំនុំជម្រះដូចខាងក្រោម៖

១.លោក [redacted] ប្រធាន

២.លោក [redacted] ចៅក្រម

៣.លោក [redacted] ចៅក្រម

៤.លោក [redacted] ចៅក្រម

៥.លោក [redacted] ចៅក្រម

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted]

**តំណាងមហាអយ្យការ**

ឯកឧត្តម [redacted] អគ្គព្រះរាជអាជ្ញារង

**ដើម្បីជំនុំជម្រះ**

លើបណ្តឹងសាទុក្ខលេខ៩៦ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] ផៃហួ និង ឈ្មោះ [redacted] សុគន្ធា ចំពោះសាលដីកាព្រហ្មទណ្ឌលេខ២៦ "ក្រIV ន" ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៩ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ដែលមាន៖

**ជនជាប់ចោទ៖**

១-ជនជាប់ចោទឈ្មោះ [redacted] ផៃហួ ភេទប្រុស អាយុ៣៥ឆ្នាំ ជាតិខ្មែរ កើតនៅភូមិស្ទឹងសែន ឃុំកំពង់ក្របៅ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ មានមុខរបរជាប្រធានសាខាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុស្ថាបនាលីមីតធីត ទីលំនៅបច្ចុប្បន្នផ្ទះលេខ [redacted] រាជធានី



Scanned with CamScanner

ភ្នំពេញ ប្រពន្ធឈ្មោះ [redacted] (រ) មានកូន០១នាក់ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ជានីតិជន ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការពីមុនគ្មាន (ក្រៅឃុំ) ។ (អ្នកប្តឹងសាទុក្ខ)

ជាប់ចោទពីបទ: រំលោភលើទំនុកចិត្តពិសេសដោយអភិបាល ប្រព្រឹត្តនៅចំណុចគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុស្ថាបនាលីមីតធីតកំចាយមា ប្រចាំខេត្តព្រៃវែង កាលអំឡុងខែកក្កដា ដល់ខែវិច្ឆិកា ឆ្នាំ២០១៥ បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ៣៩៣ នៃក្រមព្រហ្មទណ្ឌ។

២-ជនជាប់ចោទឈ្មោះ [redacted] សុគន្ធា ភេទស្រី អាយុ៣៣ ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅ [redacted] រាជធានីភ្នំពេញ ប្តីឈ្មោះ [redacted] "រ" មានកូន០១ នាក់ (ក្រៅឃុំ) ។ (អ្នកប្តឹងសាទុក្ខ)

ជាប់ចោទពីបទ: សមគំនិតក្នុងការប្រព្រឹត្តអំពើរំលោភលើទំនុកចិត្តពិសេសដោយអភិបាល ប្រព្រឹត្តនៅចំណុចគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុស្ថាបនាលីមីតធីតកំចាយមា ប្រចាំខេត្តព្រៃវែង កាលពីអំឡុងខែកក្កដា ដល់ខែវិច្ឆិកា ឆ្នាំ២០១៥ បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា២៩ និងមាត្រា៣៩៣ នៃក្រមព្រហ្មទណ្ឌ ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] មុនី តំណាងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុស្ថាបនាលីមីតធីត។

I-អំពីអង្គហេតុ

កាលពីថ្ងៃអំឡុងខែកក្កដា ឆ្នាំ២០១៥ ឈ្មោះ [redacted] ផៃហ្វ ភេទប្រុស ដែលជាប្រធានសាខាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុស្ថាបនាលីមីតធីត កំចាយមារ ប្រចាំខេត្តព្រៃវែង បានអនុម័តឥណទានឲ្យឈ្មោះ [redacted] សុគន្ធា ជាប្រពន្ធជាច្រើនលើកច្រើនសារ ដោយសារខុសនឹងគោលការណ៍ របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុស្ថាបនាលីមីតធីត គឺមិនបានជូនដំណឹងឲ្យក្រុមហ៊ុនដឹងឡើយ។ មិនតែប៉ុណ្ណោះក្នុងអំឡុងខែកក្កដា ដល់ខែវិច្ឆិកា ឆ្នាំ ២០១៥ ដដែល ឈ្មោះ [redacted] ផៃហ្វ បានអនុម័តឥណទានឲ្យប្រជាពលរដ្ឋប្រមាណ៩២គ្រួសារ ដែលមានលក្ខណ:មិនប្រក្រតី ដោយឥណទានសម្រាប់គ្រួសារនីមួយៗមានដល់ទៅចំនួន១០.០០០$ (មួយម៉ឺនដុល្លារអាមេរិក)។ បន្ទាប់មកមីក្រូហិរញ្ញវត្ថុស្ថាបនាលីមីតធីត បានកោះហៅឈ្មោះ [redacted] ផៃហ្វ មកពិភាក្សាអំពីការមិនប្រក្រតីនេះ តែជននេះមិនព្រមចូលខ្លួនដោះស្រាយថែមទាំងគេចខ្លួនរហូតដល់សព្វថ្ងៃនេះ ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ៥៨៦ "ត" ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៧ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារដូចតទៅ៖

១-ផ្តន្ទាទោស

ក.ឈ្មោះ [redacted] ផៃហ្វ ភេទប្រុស អាយុ៣៥ឆ្នាំ ដាក់ទោសពន្ធនាគារកំណត់រយ:ពេល០២(ពីរ)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៤,០០០,០០០ (បួនលាន) រៀល ពីបទ៖ រំលោភលើទំនុកចិត្តពិសេសដោយអភិបាល ឬបុគ្គលផ្សេងទៀត បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ៣៩៣ នៃក្រមព្រហ្មទណ្ឌ។

ខ.ឈ្មោះ [redacted] សុគន្ធា ភេទស្រី អាយុ៣៣ ឆ្នាំ ដាក់ទោសពន្ធនាគារកំណត់រយ:ពេល០២ (ពីរ) ឆ្នាំ



Scanned with CamScanner

ពីបទ សមគំនិតក្នុងអំពើរំលោភលើទំនុកចិត្តពិសេសដោយអភិបាល ឬបុគ្គលផ្សេងទៀត បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា២៩ និងមាត្រា៣៩៣ នៃក្រមព្រហ្មទណ្ឌ ។

២-ឱ្យឈ្មោះ [redacted] ផៃហួ និងឈ្មោះ [redacted] សុគន្ធា រួមសងសំណងជំងឺចិត្តឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីចំនួន២០,០០០,០០០ (ម្ភៃលាន) រៀល ការទាមទារលើសពីនេះត្រូវបដិសេធចោល។

សាលក្រមនេះជំនុំជម្រះ នៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៧ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៧ ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី និងកំបាំងមុខជនជាប់ចោទ។

ទុកសិទ្ធិប្តឹងទាស់ និងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

-បានឃើញ បណ្តឹងឧទ្ធរណ៍លេខ២៣៨ ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៧ របស់ជនជាប់ចោទឈ្មោះ [redacted] ផៃហួ ដែលប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ៥៨៦ “ត” ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ ២០១៧ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

-បានឃើញ បណ្តឹងឧទ្ធរណ៍លេខ២៣៩ ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៧ របស់ជនជាប់ចោទឈ្មោះ [redacted] សុគន្ធា ដែលប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ៥៨៦ “ត” ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ ២០១៧ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

-បានឃើញ បណ្តឹងឧទ្ធរណ៍លេខ២៤២ ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៧ របស់លោក [redacted] ប៉ូលី ជាមេធាវីការពារសិទ្ធិឱ្យធនាគារស្ថាបនាលីមីតធីត ដែលប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ៥៨៦ “ត” ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៧ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

-បានឃើញ សាលដីកាព្រហ្មទណ្ឌ២៦ ក្រIV“ទ” ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៩ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១-ក.ទទួលបណ្តឹងឧទ្ធរណ៍លេខ២៣៨ និងលេខ២៣៩ ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៧ របស់ឈ្មោះ [redacted] ផៃហួ និងឈ្មោះ [redacted] សុគន្ធា ជាជនជាប់ចោទ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។

ខ.ទទួលបណ្តឹងឧទ្ធរណ៍លេខ២៤២ ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៧ របស់លោក [redacted] ប៉ូលី ជាមេធាវីការពារសិទ្ធិឱ្យធនាគារស្ថាបនាលីមីតធីត ទុកជាត្រឹមត្រូវតាមច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ៥៨៦“ត” ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ លើកលែងតែចំណុចទី២ នៃសេចក្តីសម្រេច ត្រូវកែប្រែពីបង្គាប់ឱ្យឈ្មោះ [redacted] ផៃហួ និងឈ្មោះ [redacted] សុគន្ធា រួមគ្នាសងជំងឺចិត្តឱ្យទៅធនាគារស្ថាបនា ចំនួន២០លានរៀល ទៅជារួមគ្នាសងជំងឺចិត្តចំនួន៤០ លានរៀល វិញ។



Scanned with CamScanner

ចំណុចផ្សេងពីនេះនៃសេចក្តីសម្រេចត្រូវរក្សាទុកដដែល។

៣-ទុកសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី ទាមទារការខូចខាតជាក់ស្តែងនៅពេលក្រោយ ។

សាលដីកានេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៩ ចំពោះមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈនៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៩។

ទុកសិទ្ធិប្តឹងសាទុក្ខតាមកំណត់ច្បាប់។

-បានឃើញ បណ្តឹងសាទុក្ខលេខ៨៦ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] ផែហួ និងឈ្មោះ [redacted] សុគន្ធា ដែលប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌសាលាឧទ្ធរណ៍លេខ២៦ ក្រIV "ទ" ចុះថ្ងៃទី ២២ ខែមីនា ឆ្នាំ២០១៩ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

## នាពេលសវនាការ

-ចៅក្រមបានអានរបាយការណ៍ ។

-តំណាងមហាអយ្យការអមតុលាការកំពូល ធ្វើសេចក្តីសន្និដ្ឋានសុំថា៖យល់ឃើញថា ជនជាប់ចោទឈ្មោះ [redacted] ផែហួ ត្រូវបានដាក់ឱ្យស្ថិតក្រោមការពិនិត្យពីបទ រំលោភលើទំនុកចិត្តពិសេសដោយអភិបាល តាមបញ្ញត្តិមាត្រា៣៩៣ នៃក្រមព្រហ្មទណ្ឌ។

-យល់ឃើញថា តាមអង្គហេតុ អំពើរបស់ជនជាប់ចោទ [redacted] ផែហួ គឺក្នុងឋានៈជាប្រធានសាខាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុស្ថាបនាលីមីតធីត បានអនុម័តឥណទានឱ្យឈ្មោះ [redacted] សុគន្ធា ជាប្រពន្ធ ជាលើកទី២ និងក្នុងអំឡុងខែកក្កដា ដល់ខែវិច្ឆិកា ឆ្នាំ២០១៥ បានអនុម័តឥណទានដល់ប្រជាពលរដ្ឋ៩២គ្រួសារ ក្នុងមួយគ្រួសារមានចំនួនទឹកប្រាក់ដល់ទៅ១០.០០០USD (មួយម៉ឺន)ដុល្លារអាមេរិក។

-យល់ឃើញថា ជនជាប់ចោទឈ្មោះ [redacted] ផែហួ បានអនុម័តឥណទានឱ្យឈ្មោះ [redacted] សុគន្ធា ចំនួន០២លើក (ក្រោយមកក្លាយជាប្រពន្ធ) និងបានសងទៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុស្ថាបនារួចហើយ ពុំមានការខូចខាតនោះទេ ពុំមានបទល្មើសនោះឡើយ។ ឯការសម្រេចឱ្យប្រជាពលរដ្ឋ៩២គ្រួសារខ្ចីឥណទាននោះ ក៏ពុំមែនជាបទល្មើសនោះដែរ ដោយពុំមានភស្តុតាងណាមួយបញ្ជាក់ថា ជនជាប់ចោទគៃបំបាត់ថវិការបស់ស្ថាប័នមីក្រូហិរញ្ញវត្ថុស្ថាបនា នោះឡើយ។ ការសម្រេចឱ្យខ្ចីខុសគោលការណ៍ ហើយមានការខូចខាត គប្បីឱ្យឈ្មោះ [redacted] ផែហួ ទទួលខុសត្រូវក្នុងរឿងរដ្ឋប្បវេណី។

-យល់ឃើញថា ជនជាប់ចោទឈ្មោះ [redacted] សុគន្ធា បានខ្ចីលុយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុស្ថាបនា តាមការអនុម័តពីឈ្មោះ [redacted] ផែហួ ហើយបានសងបំណុលរួចរាល់ហើយ ពុំមែនជាបទ សមគំនិត នោះទេ។

-យល់ឃើញថា ជនជាប់ចោទឈ្មោះ [redacted] ផែហួ និង [redacted] សុគន្ធា មិនបានដាក់សារណាបញ្ជាក់ពីមូលហេតុនៃបណ្តឹងសាទុក្ខរបស់ខ្លួន តាមបញ្ញត្តិមាត្រា៤៣៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌឡើយ។

Scanned with CamScanner

តំណាងមហាអយ្យការ ស្នើក្រុមប្រឹក្សាជំនុំជម្រះសម្រេច៖

-តំណាងមហាអយ្យការ សូមទុកជូនក្រុមប្រឹក្សា សម្រេចតាមច្បាប់។

-ក្រោយពីបានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១-យល់ឃើញថា បណ្ដឹងសាទុក្ខលេខ៩៦ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] ផៃហ្វ និង [redacted] សុគន្ធា ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើកយករឿងនេះមកជំនុំជម្រះបាន តាមមាត្រា៦៤ នៃច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ និងមាត្រា៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២.យល់ឃើញថា ជនជាប់ចោទឈ្មោះ [redacted] ផៃហ្វ និង [redacted] សុគន្ធា ជាអ្នកប្ដឹងសាទុក្ខប្រឆាំង និង សាលដីកាព្រហ្មទណ្ឌលេខ២៦ ក្រIV"ន" ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ប៉ុន្តែនៅក្នុងដំណាក់កាលនៃនីតិវិធីចាត់ការសំណុំរឿងនៃតុលាការកំពូល តុលាការកំពូល បានចេញលិខិតបង្គាប់ឱ្យជនជាប់ចោទធ្វើសារណាការពារ ដាក់ជូនមកតុលាការកំពូល តាមការកំណត់ចំនួនពីរលើក គឺលើកទី១ នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៩ និងលើកទី២ នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩ ប៉ុន្តែជនជាប់ចោទដែលជាអ្នកប្ដឹងសាទុក្ខ មិនបានធ្វើសារណាការពារ ដាក់ជូនមកតុលាការកំពូលទេ ។ ដូច្នេះអនុលោមតាមស្មារតីមាត្រា៤៣៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ តុលាការកំពូល ពុំអាចសម្រេចលើបញ្ហាច្បាប់ ដែលអ្នកប្ដឹងសាទុក្ខ ពុំបានសសេររៀបរាប់នៅក្នុងសារណារបស់ខ្លួននោះទេ។

៣-យល់ឃើញថា តំណាងមហាអយ្យការបានចេញដីកាកោះហៅ គូភាគីឱ្យមកចូលរួមសវនាការ ប៉ុន្តែគូភាគីអវត្តមាន។ បើទោះបីគូភាគីអវត្តមានក៏ដោយ ក៏តុលាការកំពូលអាចបន្ត សវនាការនេះបានដែរ ដោយយោងតាមស្មារតីមាត្រា៤៣៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៤-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ២៦ ក្រIV "ន" ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍រាជធានីភ្នំពេញ ដែលបានសម្រេចសេចក្ដីមកនេះ ត្រឹមត្រូវតាមគតិច្បាប់។

## ហេតុដូច្នេះ

## សម្រេច

១-បដិសេធ បណ្ដឹងសាទុក្ខលេខ៩៦ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] ផៃហ្វ និងឈ្មោះ [redacted] សុគន្ធា។

Scanned with CamScanner

២-តម្កល់ សាលដីកាព្រហ្មទណ្ឌលេខ២៦ ក្រ IV "ន" ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ រាជធានីភ្នំពេញ ទុកជាបានការពេញទាំងមូល។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០។

Scanned with CamScanner